ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
លេខ : ១២៩៥/២១ អ គ រ

ថ្ងៃសៅរ៍ ១០កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២១

**ជម្រាបមក**

**លោក លោកស្រីប្រធាននាយកដ្ឋាន សាខា និងការិយាល័យគយនិងរដ្ឋាករ**

**កម្មវត្ថុ:** អំពីការលើកលែងបម្រាមលើការនាំចូលសាច់បង្កក និងមុខទំនិញបង្កកដែលអាចមានហានិភ័យផ្សេងទៀតមានប្រភពមកពីប្រទេសឥណ្ឌា ។

**យោង÷** - ចំណារដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** លើលិខិតលេខ ៤៦៨២ សហវ ចុះថ្ងៃទី១៦ ខែ មិថុនា ឆ្នាំ ២០២១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- លិខិតលេខ ៤៧៦៦ សហវ ចុះថ្ងៃទី១៨ ខែ មិថុនា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបមកលោក លោកស្រី ជ្រាបថា យោងតាមស្ថានភាពធូរស្រាលនៃការឆ្លងរាលដាលជម្ងឺកូវីដ-១៩ នៅប្រទេសឥណ្ឌា និងលទ្ធផលអវិជ្ជមាននៃការធ្វើតេស្តលើសាច់បង្កកនាពេលកន្លងមក រាជរដ្ឋាភិបាលបានសម្រេចលើកលែងបម្រាមលើការនាំចូលសាច់បង្កក និងមុខទំនិញបង្កក ដែលអាចមានហានិភ័យផ្សេងទៀតមានប្រភពមកពីប្រទេសឥណ្ឌា ដោយដាក់មកជំនួសវិញនូវវិធានការបណ្តោះអាសន្នដូចខាងក្រោម ÷

១. តម្រូវឱ្យមានវិញ្ញាបនបត្រ ឬ លិខិតបញ្ជាក់បន្ថែមចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដើមកំណើតទំនិញ ដែលបញ្ជាក់ថា គ្មានវីរុសកូវីដ-១៩ លើសាច់បង្កក
២. នៅពេលទំនិញមកដល់ តម្រូវឱ្យយកសំណាកធ្វើតេស្តរកវីរុសកូវីដ-១៩ ដោយវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា មុនអនុញ្ញាតឱ្យបំពេញបែបបទបញ្ចេញទំនិញពីគយ ។

យោងតាមពេលវេលា និងការវិវត្តជាក់ស្តែង ការអនុវត្តលក្ខខណ្ឌទាំង ២ ខាងលើនេះ អាចនឹងត្រូវបន្ធូរបន្ថយ ឬដកចេញទាំងស្រុង ផ្អែកលើស្ថានភាពធូរស្រាលនៃការរីករាលដាលជំងឺកូវីដ-១៩ នៅប្រទេសនាំចេញ និងលទ្ធផលនៃការធ្វើតេស្តលើសាច់បង្កកដោយវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា បើរកឃើញថា *អវិជ្ជមាន* ជាបន្តបន្ទាប់ ។ ក្នុងន័យនេះ សូមលោក លោកស្រី ធ្វើរបាយការណ៍ប្រចាំខែមកអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដើម្បីមានមូលដ្ឋានសម្រាប់ពិចារណាការបន្ធូរបន្ថយ ឬដកចេញទាំងស្រុងនៃវិធានការបណ្តោះអាសន្នទាំង២ខាងលើនេះ នាថ្ងៃមុខ ។

អាសយដ្ឋាន: លេខ ៦-៨ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ / ទូរសារ: (៨៥៥-២៣) ២១៤ ០៦៥ / ៧២៥ ១៨៧ / ២១២ ៤៥៧ / E-mail: info-pru@customs.gov.kh

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមអស់លោក លោកស្រីចាត់ចែងផ្សព្វផ្សាយដល់ពាណិជ្ជករ/ធុរៈជនពាក់ព័ន្ធ និងអនុវត្តតាមខ្លឹមសារដូចមានចែងក្នុងលិខិតនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០២១ តទៅ រហូតដល់មានការណែនាំជាថ្មី ។

សូមលោក លោកស្រី ទទួលនូវការស្រលាញ់រាប់អានពីខ្ញុំ

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**អគ្គនាយកគយ និងរដ្ឋាករកម្ពុជា**

**បណ្ឌិត គុណ_ញឹម**

**<u>ចម្លងជូន÷</u>**

- ខុទ្ទកាល័យឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សភាពាណិជ្ជកម្មកម្ពុជា
  "ដើម្បីសហការផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ